COUNT US IN 2020

There's Power In Being Counted

ASIAN AMERICANS ADVANCING JUSTICE

COUNTUSIN2020.ORG

# ការបញ្ចូលមិត្តភក្តិ និងគ្រួសាររបស់លោកអ្នកនៅក្នុងជំរឿនឆ្នាំ 2020

*មានសំណួរមែនទេ? សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍ផ្នែកជំរឿនរបស់យើង តាមលេខ 844-2020-API សម្រាប់ជំនួយគាំទ្រជាភាសាអង់គ្លេស និងភាសាដទៃផ្សេងទៀត។ សូមចូលមើលគេហទំព័រ www.CountUsIn2020.org/hotline សម្រាប់ព័ត៌មានបន្ថែម។*

ការធ្វើជំរឿនចាប់ផ្តើមនៅខែមីនា ឆ្នាំ 2020។ ***ត្រូវប្រាកដថា លោកអ្នក និងសហគមន៍របស់លោកអ្នកត្រូវបានរាប់ដើម្បីទទួលបានចំណែកស្មើភាពនៃធនធាន និងការតំណាងរបស់លោកអ្នក!***
ជារៀងរាល់ 10 ឆ្នាំម្តង

រដ្ឋាភិបាលសហរដ្ឋអាមេរិកធ្វើការរាប់ចំនួនមនុស្សគ្រប់រូបដែលរស់នៅក្នុងសហរដ្ឋអាមេរិក។ កម្រងសំណួរជំរឿនគឺខ្លី ហើយចម្លើយផ្ទាល់ខ្លួនរបស់លោកអ្នកគឺជាការសម្ងាត់។ ***លោកអ្នកគឺជាអ្នកផ្ញើសារដ៏ល្អបំផុត និងគួរឱ្យទុកចិត្តបំផុតចំពោះមិត្តភក្តិ និងក្រុមគ្រួសាររបស់លោកអ្នក។***

សូមជួយសហគមន៍របស់លោកអ្នកតាមរយៈការនិយាយជាមួយមិត្តភក្តិ និងគ្រួសាររបស់លោកអ្នកអំពីការធ្វើជំរឿននេះ៖

## ជំរឿនមានសារៈសំខាន់សម្រាប់ខ្ញុំពីព្រោះ...

- ការរាប់ជំរឿនជួយកំណត់ថាតើ ថវិកាប៉ុន្មានដែលត្រូវផ្តល់ដល់សេវាកម្មនានាដូចជា សាលារៀន មន្ទីរពេទ្យ និងផ្លូវហាយវេ - ចំនួនមនុស្សត្រូវបានរាប់កាន់តែច្រើននៅក្នុងសហគមន៍របស់យើង យើងនឹងទទួលបានថវិកាកាន់តែច្រើនដែរ។
- លទ្ធផលជំរឿនកំណត់ភាពជាតំណាងផ្នែកនយោបាយ រួមទាំង ចំនួនអាសនៈនៅក្នុងសភាដែលរដ្ឋរបស់យើងនឹងទទួលបាន និងរបៀបដែលស្រុកត្រូវបានដកសម្រាប់រដ្ឋាភិបាលរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន។
- រដ្ឋាភិបាល អាជីវកម្ម និងអង្គភាពសហគមន៍ប្រើប្រាស់ទិន្នន័យជំរឿនដើម្បីបែងចែកថវិកា ធនធាន និងសេវាកម្មនានាដល់សហគមន៍របស់យើង និងសម្រេចថាត្រូវវិនិយោគនៅចំណុចណា។

## ការចូលរួមក្នុងជំរឿនគឺមានសុវត្ថិភាព។

- ចម្លើយជំរឿនរបស់យើងគឺជាការសម្ងាត់។ តាមច្បាប់ ការិយាល័យជំរឿនមិនអាចចែករំលែកចម្លើយរបស់យើងជាមួយនរណាម្នាក់បានឡើយ ដោយរាប់បញ្ចូលទាំង ទីភ្នាក់ងាររដ្ឋាភិបាលសហព័ន្ធ រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន ឬផ្នែកអនុវត្តច្បាប់អន្តោប្រវេសន៍។

## ការចូលរួមក្នុងជំរឿនគឺសាមញ្ញ។

- ត្រូវប្រាកដថារាប់មនុស្សគ្រប់រូបដែលរស់នៅក្នុងផ្ទះគិតត្រឹមថ្ងៃទី1 ខែមេសា ឆ្នាំ 2020 ដោយមិនគិតពីទំនាក់ទំនងរបស់ពួកគេជាមួយលោកអ្នក! ការនេះរួមបញ្ចូលទាំង ទារក កុមារតូចៗ សាច់ញាតិ មិត្តរួមបន្ទប់ និងមិត្តភក្តិ។ មនុស្សគ្រប់រូបត្រូវបានរាប់នៅក្នុងជំរឿន។

- ប្រជាជនសឹងគ្រប់គ្នានឹងទទួលបានការអញ្ជើញឲ្យបំពេញជំរឿនតាមអនឡាញនៅពាក់កណ្ដាលខែមីនា ឆ្នាំ2020។ លោកអ្នកក៏អាចទូរស័ព្ទទៅការិយាល័យជំរឿនដើម្បីផ្ដល់ចម្លើយរបស់លោកអ្នកតាមទូរស័ព្ទបានផងដែរ។ ប្រសិនបើលោកអ្នកមិនឆ្លើយតបតាមអនឡាញ ឬតាមទូរស័ព្ទទេ ការិយាល័យជំរឿននឹងផ្ញើទម្រង់បែបបទមួយច្បាប់មកអ្នកតាមសំបុត្រប្រៃសណីយ៍។
- ប្រសិនបើលោកអ្នកមិនឆ្លើយតបទៅនឹងជំរឿនទេ ការិយាល័យជំរឿនអាចនឹងបញ្ជូនមន្ត្រីជំរឿនទៅដល់ផ្ទះរបស់លោកអ្នកដើម្បីប្រមូលព័ត៌មានរបស់លោកអ្នកដោយផ្ទាល់ - ដូច្នេះប្រសិនបើលោកអ្នកមិនចង់អោយមន្ត្រីជំរឿនទៅដល់ផ្ទះរបស់លោកអ្នកទេ សូមបំពេញជំរឿនអោយបានកាន់តែឆាប់តាមដែលអាចធ្វើបាន!

សូមជួយយើងផ្សព្វផ្សាយអំពីសារៈសំខាន់នៃជំរឿនសម្រាប់យើងទាំងអស់គ្នាដើម្បីធ្វើឱ្យប្រាកដថាយើងទាំងអស់គ្នាត្រូវបានរាប់នៅក្នុងជំរឿនឆ្នាំ2020!

*អ្នកអាចស្វែងរកព័ត៌មានបន្ថែមទៀតអំពីជំរឿននៅ www.CountUsIn2020.org/resources*។